01

LA FRESQUE DU SOL
THE SOIL COLLAGE

ខ្ញុំជាអង្គធាតុរាវ ខ្ញុំសាយភាយនិងស្ថិតនៅក្នុងរន្ធតូចៗនៃដី
ខ្ញុំនៅលាយលំជាមួយនឹងកំទិចកំទីដី
ភាវៈមានជីវិតទាំងអស់មិនថា កូនរុក្ខជាតិ និងសត្វល្អិតក្នុងដី
សុទ្ធសឹងតែកើតឡើងដោយសារខ្ញុំ ប្រសិនបើគ្មានខ្ញុំទេ  វា
មិនអាចរស់រានមានជីវិតបានឡើយ។

**ខ្ញុំគឺជា...**

# ទឹក



LA FRESQUE DU SOL
THE SOIL COLLAGE

អ្នកមិនអាចមើលឃើញខ្ញុំ និងមិនអាចប៉ះខ្ញុំបាន។ ខ្ញុំកើតឡើង
ពីឧស្ម័ន ហើយបានទៅបំពេញនៅរាល់ចន្លោះទាំងអស់នៃដី
ដែលមិនអាចបំពេញដោយទឹកបាន។
ខ្ញុំមានសារៈសំខាន់ណាស់ចំពោះជីវិតទាំងអស់នៅក្នុងដី។

**ខ្ញុំគឺជា**

# ខ្យល់



03

យើងលូតលាស់នៅក្នុងដី និងនៅលើផ្ទៃដី។
ឫសរបស់យើងមានសារៈសំខាន់ណាស់ វាបាននាំយកទឹក
និងសារធាតុរ៉ែមកឲ្យយើង។ យើងអាចយកឧស្ម័នកាបូនពីខ្យល់
ហើយបានយកវាបំលែងវាទុកនៅក្នុងដី តាមការធ្វើរស្មីសំយោគ។

**យើងគឺជា...**

# កូនរុក្ខជាតិ



LA FRESQUE DU SOL
THE SOIL COLLAGE

យើងស៊ីសំណល់សរីរាង្គ និងចូលរួមចំណែកក្នុងការបំបែកវា។
មនុស្សមិនអាចមើលយើងឃើញដោយភ្នែកទទេបានទេ
យើងរស់នៅក្នុងដី ក៏ដូចជាក្នុងរាងកាយមនុស្ស
ប្រសិនបើគ្មានយើងទេ ដី
និងមនុស្សមិនអាចធ្វើដំណើរការផ្សេងៗបានឡើយ។

**យើងគឺជា...**

# មីក្រូសារពាង្គកាយ


04
បាក់តេរី = Thiomonas arsenivorans
DImacell 3.0kV 10.1mm x9.00k SE(U)
5.00µm

05

ខ្ញុំគឺជាអាហាររបស់ភាវៈរស់ជាច្រើននៅក្នុងដី។

ខ្ញុំចេញមកពីកម្ទេចកម្ទីនៅលើផ្ទៃដី និងនៅក្នុងដី
ខ្ញុំត្រូវបានកើតឡើងពីតំណរភ្ជាប់នៃសមាសភាពកាបូន
ខ្ញុំមានទម្រង់ជាសារពាង្គកាយមានជីវិត ឬស្លាប់ ការរលួយតិច
ឬច្រើន។

**ខ្ញុំគឺជា...**

# សំណល់សរីរាង្គ

05



សំណល់សរីរាង្គដែលមិនទាន់រលួយ

06

ខ្ញុំសំដៅទៅលើសត្វល្អិតៗទាំងអស់នៅក្នុងដី។

ឧទា. ខ្ញុំបានចូលរួមចំណែកក្នុងការកែច្នៃនៃសំណល់សរីរាង្គ ឬការបង្កើតនៃរន្ធតូចៗនៅក្នុងដី...

**ខ្ញុំគឺជា...**

# សត្វល្អិតនៅក្នុងដី

06



ជន្លេន Anecium ធំពេញលេញមានទំហំពី ២ ទៅ ៣០សង់ទីម៉ែត្រ ឬក៏ធំជាងនេះ។

07

LA FRESQUE DU SOL

THE SOIL COLLAGE

រឹង ឬពុកផុយ, ខ្ញុំគឺជាដើមកំណើតនៃដី។ ខ្ញុំផ្ទុកសារធាតុរ៉ែ ដែលភាគច្រើនត្រូវបានរកឃើញនៅក្រោមដី និងផ្តល់ជាពណ៌ឲ្យដី ដោយផ្ទាល់ឬបន្ទាប់ពីការកែច្នៃ។

គ្រប់សមាសធាតុរបស់ខ្ញុំមានសារៈសំខាន់ណាស់សម្រាប់ការកកើត សណ្ឋានដី និងរចនាសម្ព័ន្ធនៃដី។

**ខ្ញុំគឺជា...**

# ថ្មផេ



08

LA FRESQUE DU SOL
THE SOIL COLLAGE

យើងត្រូវបានរៀបចំជាស្រទាប់តូចៗ។ ឧទា.
គេប្រើយើងនៅក្នុងការស្ទូន។

យើងកើតចេញពីការវិវដ្តន៍នៃកម្ទេចកម្ទីរបស់ថ្មមេ។

**ខ្ញុំគឺជា...**

# ដីឥដ្ឋ

08



09

ខ្ញុំមានតួនាទីក្នុងការប្រមូលផ្តុំកំទេចកម្ទីដែលមានវត្តមាននៅក្នុងដី
( ដីខ្សាច់ ដីល្បាប់ ដីឥដ្ឋ និងសំណល់សរីរាង្គ )
ឲ្យផ្តុំចូលគ្នាដោយឯកឯង, ការរួមបញ្ចូលគ្នានេះមានន័យថាគឺ
ការប្រមូលផ្តុំនូវរាល់បំណែកតូចៗទាំងអស់
រួមទាំងរន្ធតូចៗផងដែរ។

ភាវៈមានជីវិតតូចៗនៅក្នុងដី
ក៏ចូលរួមចំណែកនៅក្នុងការកកើតនេះផងដែរ( បាក់តេរី
មេរោគផ្សិត ជន្លេន។ល។)

# រចនាសម្ព័ន្ធ (ការតោងភ្ជាប់)

09



អ្នកអាចវិភាគខ្ញុំបានដោយដាក់ដីបន្តិចនៅលើដៃ។ ខ្ញុំមានភាពទន់ ឬរឹង ឬគ្រើម ឬស្អិត ឬស្រួយ...

ខ្ញុំអាចជាភក់ ដីល្បាប់ ឬក៏ដីខ្សាច់ អាស្រ័យលើទំហំ និងបរិមាណនៃភាគល្អិតដែលខ្ញុំមាន។ ខ្ញុំជួយសម្រួល ឬក៏រាំងស្ទះដល់ចរន្តទឹក ខ្យល់ និងការរស់នៅរបស់ភាវៈមានជីវិតនៅក្នុងដី

**ខ្ញុំគឺជា...**

# សណ្ឋានដី



10

11

យើងជាបណ្តុំនៃដីឥដ្ឋ (ពេលខ្លះអាចជាដីល្បាប់សុទ្ធ)
និងសំណល់សរីរាង្គ។ យើងអាចកើតឡើងដោយឯកឯង
ប៉ុន្តែក៏មកពីសកម្មភាពរបស់ភាវៈរស់ក្នុងដីផងដែរ។

យើងជួយធ្វើអោយការតោងភ្ជាប់របស់ភាគល្អិតនៃដីកាន់តែរឹងមាំ

និងរក្សាលំនឹង
ដល់ការរស់នៅរបស់ភាវៈរស់ក្នុងដីនៅពេលដែលមានបម្រែបម្រួល
ការកកើតឡើង។

**ខ្ញុំគឺជា...**

# បណ្តុំរ៉ែខនិជ

11



12

LA FRESQUE DU SOL
THE SOIL COLLAGE

ខ្ញុំគឺជាចន្លោះទាំងប៉ុន្មានដែលមាននៅក្នុងដី
ដោយពុំមែនភាគល្អិតណាមួយនៃដីនោះទេ។
ដូច្នេះគ្រប់ចន្លោះរបស់ខ្ញុំគឺអាចផ្ទុក ឬឱ្យមានលំហូរ ទឹក
និងខ្យល់អាចឆ្លងកាត់បាន។

**ខ្ញុំគឺជា...**

# ចន្លោះប្រហោងរវាងភាគល្អិតនៃដី



LA FRESQUE DU SOL
THE SOIL COLLAGE

ខ្ញុំមានតួនាទីយ៉ាងសំខាន់ក្នុងកំណកំណើតដី
ប៉ុន្តែខ្ញុំបានមិននៅក្នុងដីទេ។
ខ្ញុំមិនអាចផ្តាច់ចេញពីបរិយាកាសបានឡើយ។

សម្រាប់មនុស្សគ្រប់គ្នា
ពួកគេនិយាយថាដីមិនមែនជាធនធានកម្រទេ។

ប្រវត្តិសាស្ត្រកើតមានឡើងដោយសារតែខ្ញុំ។

**ខ្ញុំគឺជា...**

# ពេលវេលា

13



14

ខ្ញុំសំដៅទៅលើគ្រប់ប្រតិកម្មរបស់មនុស្ស, ប្រតិកម្មគីមី,
និងប្រតិកម្មជីវ
ដែលទទួលខុសត្រូវលើការផ្លាស់ប្តូររបស់កំទិចកម្ទីថ្មមេ
ដែលមាននៅក្នុងដីបន្ទាប់ពីមានការប្រែប្រួល។

ខ្ញុំមានឥទ្ធិពលនៅពេលដែលអាកាសធាតុ ធាតុអាកាស ជម្រាលធម្មជាតិ និងសកម្មភាពរបស់ថ្ម និងភាវៈមានជីវិតនៅក្នុងដី និងភាពខុសគ្នាក្នុងការប្រើប្រាស់ដីតាមកន្លែងរបស់វា។

**ខ្ញុំគឺជា...**

# ការកកើតនៃដី





ខ្ញុំមានតួនាទីយ៉ាងសំខាន់ក្នុងការកកើតដី (ដំណើរការ និងពេលវេលា ក្នុងការកំណកំណើតដី និងការលូតលាស់)។

ខ្ញុំអាចជា ទ្វីប មហាសមុទ្រ វាលខ្សាច់ មេឌីទែរ៉ាណេ...

**ខ្ញុំគឺជា...**

# អាកាសធាតុ


15
Polar zone
Subarctic zone
Temperate zone
Subtropical zone
Tropical zone
Equatorial zone

# ការត្រួត, ការរក្សាទុក, និងបន្ថយសារធាតុបំពុល

16



LA FRESQUE DU SOL
THE SOIL COLLAGE

អាស្រ័យលើកត្តាធម្មជាតិ និងគុណភាពរបស់ដី (រចនាសម្ព័ន្ធ, សណ្ឋានដី មុខងាររបស់សំណល់សរីរាង្គ។ល។), ដីមានលក្ខណៈខុសគ្នាច្រើនណាស់។

សារធាតុកខ្វក់អាចច្រោះ ឃាត់ ឬបន្ថយបាន។ សារធាតុបំពុលមួយចំនួនអាចមាននៅសេសសល់ក្នុងដីរយៈពេលយូរ។

**ខ្ញុំគឺជា...**

# ការស្តុកទុក, ការកែច្នៃ, ការផ្លាស់ប្តូររបស់សំណល់សរីរាង្គ

17



LA FRESQUE DU SOL
THE SOIL COLLAGE

ដី

និងកូនរុក្ខជាតិពឹងផ្អែកលើគ្នាទៅវិញទៅមកដោយទទួលបានគុណសម្បត្តិរៀងៗខ្លួន។ ម៉្យាងវិញទៀតកូនរុក្ខជាតិបាននាំយកសំណល់សរីរាង្គទៅឲ្យដី ( សំរាម ឬស ផលិតផលធម្មជាតិ ), និងម៉្យាងទៀតដីមានតួនាទីជាជំនួយ និង”កន្លែងស្តុកទុក” របស់កូនរុក្ខជាតិ( ទឹក សារធាតុចិញ្ចឹម ភាវៈមានជីវិត )។ កូនរុក្ខជាតិបង្កើតស្លឹក មែក និងឬសរបស់ពួកគេតាមរយៈការធ្វើរស្មីសំយោគ ដោយការប្រើប្រាស់កាបូនដែលមាននៅក្នុងបរិយាកាស។ នៅពេលដែលពួកវាងាប់ កាបូនទាំងនេះនឹងប្រែប្រួល ផ្ទេរ ឬក៏ស្តុកវាទុកនៅក្នុងដី និងអោយទៅរចនាសម្ព័ន្ធរបស់វា។

**ដើម្បីដឹងពីព័ត៌មានបន្ថែម**

**ចូលរួមក្នុងកម្មវិធី The Ling Sol Workshop**

# ជម្រករបស់សត្វរស់



LA FRESQUE DU SOL
THE SOIL COLLAGE

ពឹងផ្អែកលើលក្ខណៈសម្បត្តិរបស់វា(រចនាសម្ព័ន្ធ រូបវិទ្យា-គីមីវិទ្យា។ល។)
ដីគឺជាប្រព័ន្ធអេកូឡូស៊ីដែលផ្តល់ជាជម្រកដល់ភាវៈមានជីវិតជាច្រើន៖ ពពួកសត្វទាំងអស់ សារពាង្គកាយតូចៗ និងកូនរុក្ខជាតិ។

ជាការពិតណាស់ មួយភាគបួននៅក្នុង ៥៩%នៃសត្វដែលរស់នៅលើផែនដីគឺរស់នៅក្នុងដី។

# ការផ្លាស់ប្តូរឧស្ម័នជាមួយនឹងបរិយាកាស

19



ដីមានឥទ្ធិពលទៅលើអាកាសធាតុតាមរយៈវដ្តទឹក និងការផ្លាស់ប្តូរឧស្ម័ន។
ការធ្វើរស្មីសំយោគរបស់រុក្ខជាតិពិតមានសារៈសំខាន់ណាស់វាបានផ្ទុកឧស្ម័នកា
ឧស្ម័នកាបូនឌីអុកស៊ីតដែលមានទម្រង់ជាសំណល់សរីរាង្គ។
វាបានទៅចាប់យកអាហារូបតាមរយៈសកម្មភាពរបស់បាក់តេរី( សម្ព័ន្ធជីវិត )។

តាមរយៈការធ្វើសកម្មភាពរបស់ភាវៈរស់ទាំងអស់ ពួកវាមានផ្ទុក( ពពួកសត្វ
និងសារពាង្គកាយតូចៗ ) តាមធម្មជាតិពួកវាបានបញ្ចេញឧស្ម័ននៅក្នុងផ្ទះកញ្ចក់
( ឧស្ម័នកាបូនឌីអុកស៊ីត ឧស្ម័នមេតាន នីត្រីសអុកស៊ីត )។
វិធីសាស្រ្តក្នុងការគ្រប់គ្រងដីជះឥទ្ធិពលទៅលើដំណើរការនេះ
និងជាហេតុនាំឲ្យមានឧស្ម័នផ្ទះកញ្ចក់មួយចំនួននៅក្នុងខ្យល់ និងបរិយាកាស។

# ការរក្សាទុកនូវសារធាតុចិញ្ចឹមសម្រាប់ការទ្រទ្រង់



20

LA FRESQUE DU SOL
THE SOIL COLLAGE

ដីស្តុកទុកនូវសារធាតុចិញ្ចឹម ដើម្បីផ្គត់ផ្គង់ដល់ មីក្រូសារពាង្គកាយពពួកសត្វល្អិតតូចៗនៅក្នុងដី និងកូនរុក្ខជាតិដូចជា៖ អាសូត ផូស្វ័រ កាលស្យូម ធាតុដាន។ល។

ធាតុទាំងទាំងអស់នេះមានការចាំបាច់ណាស់ក្នុងការលូតលាស់របស់ពួកគេ។

# ដីមានលំនឹងគឺ ជួយគាំពារដល់ភាវៈរស់



ដោយសារតែលក្ខណៈសម្បត្តិរបស់វា(សណ្ឋានដី រចនាសម្ព័ន្ធ
កម្រាស់ ។ល។) ដីផ្តល់នូវលំនឹងសម្រាប់ការគាំពារ
និងទ្រទ្រង់ដល់ការលូតលាស់របស់រុក្ខជាតិ(ការចាក់ឫស
និងការលូតលាស់របស់ឫស) ពពួកសត្វ
និងមីក្រូសារពាង្គកាយ(ឧទា. រូងក្នុងដី និងលើដី)។

# កន្លែងស្តុកទឹក លំហូរនៃទឹក និងការជ្រាបចូលនៃទឹក

22



LA FRESQUE DU SOL
THE SOIL COLLAGE

ទឹកអាចផ្ទុកបានតិច ឬច្រើន ជ្រាបចូលទៅតាមរន្ធដី ឬហូរចេញវា អាស្រ័យទៅលើធម្មជាតិនៃដី។

ដូច្នេះដីមានតួនាទីយ៉ាងសំខាន់នៅក្នុងវដ្តទឹក។

# ទប់ស្កាត់ចម្រោះដី និងការបាក់ដី



LA FRESQUE DU SOL
THE SOIL COLLAGE

ការប្រើប្រាស់ និងការចាត់ចែងរបស់យើងអាចកាត់បន្ថយ
ការច្រោះដី និងការបាក់ដី។

លក្ខណៈសម្បត្តិរបស់វា(រន្ធតូចៗ រចនាសម្ព័ន្ធ។ល។)
មានតួនាទីយ៉ាងសំខាន់ក្នុងការរក្សាលំនឹងនៃដី។

ការរក្សាទុកគឺជួយជ្រោមជ្រែងដោយអ្នកប្រើប្រាស់(វាលស្មៅ
ដីស្រទាប់លើ។ល។) ដែលការពារទាំងសាច់ដី
និងស្ថេរភាពនៃដី(ឫស មេរោគផ្សិត សារធាតុរ៉ែសំខាន់ៗ ។ល។

# ការទប់ស្កាត់មេរោគ និងសត្វល្អិត



LA FRESQUE DU SOL
THE SOIL COLLAGE

ដីគឺជាជម្រករបស់ប្រព័ន្ធអេកូឡូស៊ីដែលបានបង្កើតតុល្យភាពរវាង សត្វមំសាសី និងសត្វរំពា។
ដូច្នេះសារពាង្គកាយនៅលើដីមានលទ្ធិភាពក្នុងការគ្រប់គ្រងការរីករាលនៃសត្វល្អិតផ្សេងៗ។

# ការផលិតជីវម៉ាស ដែលមិនមែនជាអាហារ



ផ្នែកមួយចំនួនរបស់ដីត្រូវបានប្រើប្រាស់សម្រាប់ផលិតជីវម៉ាស

ដែលមិនមែនជាអាហារ។

ពួកវាត្រូវប្រើប្រាស់សម្រាប់ផលិតគ្រឿងវាយនភណ្ឌ(កប្បាស ដើមក្រចៅ។ល។) ឥន្ធនៈ(ជីវអេតាណុល) សម្ភារៈសំណង់(ផ្ទឹម) គ្រឿងសង្ហារឹម ទ្រនាប់មិនចម្លងកំដៅ (អ៊ីសូឡង់) ថាមពល ។ល។

*ដើម្បីស្វែងយល់បន្ថែមពីបញ្ហាដែលពាក់ព័ន្ធសូមចូលរួមក្នុង

Forest Collage

# ការផលិតអាហារ

26



ដីគឺមានសារសំខាន់ណាស់ដល់ការផលិតអាហាររបស់មនុស្ស ៩៥%នៃអាហាររបស់យើងទទួលបានដោយផ្ទាល់ ឬដោយប្រយោលមកពីដី។

ប្រព័ន្ធផលិតកម្ម និងដំណើរការបច្ចេកទេសគឺមានភាពចម្រុះ និងប៉ះពាល់ដល់ដីតាមរបៀបផ្សេងៗគ្នា។

ការអភិរក្សដីជាបញ្ហាស្នូលដែលផ្ទេកចំណីអាហារពិភពលោក កំពុងប្រឈមមុខ។

*ដើម្បីស្វែងយល់បន្ថែមពីបញ្ហាដែលពាក់ព័ន្ធសូមចូលរួមក្នុង Agri’Alim Collage ឬ Food Collage។

# ការទាញយកជាតិប្រៃ



LA FRESQUE DU SOL
THE SOIL COLLAGE

# ការទាញយកជាតិប្រៃពីដី

វាទាក់ទងនឹងការកើនឡើងនៃជាតិរ៉ែនៅក្នុងដី( សូដ្យូម ប៉ូតាស្យូម ម៉ាញេស្យូម កាល់ស្យូម ក្លរួ ស៊ុលផាត និងអ៊ីកាបូណាត )។ វត្តមាននៃជាតិប្រៃទាំងនេះប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សារពាង្គកាយតូចៗ ក៏ដូចជាការលូតលាស់របស់រុក្ខជាតិ និងធ្វើឲ្យដីគ្មានជីវជាតិ និងកង្វក់ទឹក។

ការទាញយកជាតិប្រៃអាចតាមរយៈធម្មជាតិនៅតាមកន្លែងនានា ប៉ុន្តែក្នុងបរិបទកសិកម្ម មូលហេតុចំបងនោះគឺការស្រោចដំណាំខុសបច្ចេកទេស។

# ការឃាត់បង់សំណល់សរីរាង្គ



28

LA FRESQUE DU SOL
THE SOIL COLLAGE

សំណល់សរីរាង្គគឺជាកត្តាសំខាន់មួយដែលធ្វើឲ្យដីមានជីវជាតិ។

បច្ចុប្បន្នការធ្វើកសិកម្ម
និងរុក្ខកម្មបានស្រូបយកសំណល់សរីរាង្គចេញពីក្នុងដី
ច្រើនជាងដែលបញ្ចូលទៅក្នុងដី។

នេះជាហេតុធ្វើឲ្យគុណភាពនៃដីត្រូវបានកាត់បន្ថយ។
(ដូចជាកាត់បន្ថយបរិមាណកាបូន បាត់បង់ជីវជាតិ
និងបង្កឱ្យមានចម្រោះដី។ល។)

# ការបង្ហាប់

29



LA FRESQUE DU SOL
THE SOIL COLLAGE

ការបង្ហាប់ដីធ្វើឲ្យខូចរចនាសម្ព័ន្ធរបស់វា និងកាត់បន្ថយរន្ធតូចៗផងដែរ។

វាធ្វើឲ្យមានផលវិបាកដែលជារើយៗទឹក និងខ្យល់ពុំអាចឆ្លងកាត់វាបាន
រុក្ខជាតិមិនអាចចាក់ឬសបាន
និងសារពាង្គកាយមួយចំនួនមិនអាចបំលាស់ទីបាន។

ការធ្វើកសិកម្ម និងរុក្ខកម្មហួសហេតុពេកវាបានធ្វើឲ្យមានកំហាត់ដី។

# អតុល្យភាពនៃសារធាតុចិញ្ចឹម - ការធ្វើឱ្យដីមានអាស៊ីត



LA FRESQUE DU SOL
THE SOIL COLLAGE

ការបន្ថែមសារធាតុចិញ្ចឹមដូចជា នីត្រូជេន ផូស្វ័រ ប៉ូតាស្យូម ទៅក្នុងដីក្នុងបរិមាណខ្ពស់ពេក ឬទាបពេក អាចបណ្តាឲ្យមានផលប៉ះពាល់អវិជ្ជមានណាមួយ ទៅលើដំណើរការរបស់វា។

អតុល្យភាពទាំងនេះ អាចធ្វើឱ្យមានការផ្លាស់ប្តូរកម្រិតមាត្រដ្ឋាន pH( ការធ្វើឱ្យដីមានអាស៊ីត )  ការបាត់បង់ជីវជាតិដី កាត់បន្ថយជីវចម្រុះ ការបំពុលទឹកជាដើម...

# ការច្រោះដី



ការច្រោះដី កើតមានឡើងនៅពេលដែលដីត្រូវបានរងឥទ្ធិពលពីខ្យល់ និងទឹកភ្លៀង។

ការប្រើប្រាស់ដីមិនបានល្អ( ការធ្វើកសិកម្ម ឬក៏រុក្ខកម្ម )អាចធ្វើឲ្យមានលំហូរចេញ នេះគឺជាសញ្ញានៃការច្រោះដី។ ក្នុងរយៈពេលដ៏ខ្លី សមត្ថភាពក្នុងការផលិតរបស់ដីត្រូវបានថយចុះដោយសារតែការផ្ទុកកាបូនរបស់វាត្រូវបានបំផ្លាញតាមលំហូរនៃទឹក។

កាច្រោះកម្រិតខ្លាំងនឹងធ្វើឲ្យដីត្រូវបានបាត់បង់ជីវជាតិគ្រប់បែបយ៉ាង និងក្លាយទៅជាកម្ទេចកំទីថ្មមេនៅរយៈពេលរាប់ពាន់ឆ្នាំ។

# ការរំលោភយកដី



32

ដីត្រូវបានគេចង់បានសម្រាប់ការប្រើប្រាស់ ទាំងការសាងសង់ និងការផលិតជីវម៉ាស។ ទាំងនេះបណ្តាលឲ្យមានការប្រកួតប្រជែង និងមិនចុះសម្រុងរវាងគ្នានឹងគ្នា។

សិទ្ធិក្នុងការប្រើដីអាចត្រូវប្រើបានដោយផ្តាច់មុខ( សំដៅលើសកម្មភាពនៃការប្រើដីក្នុងតំបន់ធំៗ) ជាពិសេសក្នុងន័យចង់បានផលប្រយោជន៍ពីថ្លៃឈ្នួលដី។

# គុណសម្បត្តិនៃទេសភាព និងកន្លែង



ជាតំបន់ដែលមិនមានការបិទបាំង( មិនចាក់បេតុង មិនក្រាលកៅស៊ូ
គ្មានដំបូល ។ល។) ដែលជាកន្លែងស្រូបយកខ្យល់អាកាស
និងជាកន្លែងកំសាន្តដែលនៅមិនឆ្ងាយពីទីប្រជុំជន។

កន្លែងទាំងនេះអាចឲ្យទឹកជ្រាបចូលបានយ៉ាងជ្រៅ
ដែលដើរតួយ៉ាងសំខាន់ក្នុងការជួយកាត់បន្ថយការឡើងកម្តៅ
និងផលប៉ះបាល់ពីទឹកជំនន់។

លើសពីនេះទៅទៀត
ទេសភាព( សំណុំនៃប្រព័ន្ធអេកូឡូស៊ីដែលទាក់ទងគ្នា )
នាំមកនូវសុខុមាលភាព និងជួយគាំពាជីវចម្រុះ
និងការវិលទៅវិលមករបស់ទឹក សារធាតុរ៉ែ ។ល។

# លក្ខណៈពិសេសរបស់ខ្យល់



LA FRESQUE DU SOL
THE SOIL COLLAGE

ដីមានសមត្ថភាពក្នុងការច្រោះ ការបំលែង
ឬក៏ផ្ទុកនូវសារធាតុពុលដែលមាននៅក្នុងបរិយាកាស( ឧស្ម័ន ធូលី)។

ការផ្តុំចូលគ្នារបស់ដីត្រូវបានផ្សាភ្ជាប់ដោយធាតុផ្សំសំខាន់ៗ
និងសារធាតុពុល ក៏ដូចជាការរស់នៅ ពាសពេញដីរបស់ភាវៈចម្រុះ។

សំណល់សរីរាង្គ និងដីឥដ្ឋបានចូលរួមការទប់ស្កាត់សារធាតុបំពុល
ដែលអាចផ្លាស់ប្តូរមុខងាររបស់ដី។

*ដើម្បីស្វែងយល់បន្ថែម សូមចូលរួមក្នុង air quality collage។

# លក្ខណៈពិសេស និងការគ្រប់គ្រងកាកសំណល់



កាកសំណល់របស់យើងត្រូវបាន
ចាត់ចែងជាម៉ូលេគុលដែលបានបង្កើតចេញពីសារធាតុគីមី។
ប្រសិនបើសារធាតុគីមីមិនបាត់ចេញទេ នោះម៉ូលេគុលដែលបានផ្ទុំអាចនឹងកែប្រែ
និងចុះអន់ខ្សោយ។ ដូច្នេះដីក៏អាចគេយកទៅប្រើជា"អ្នករំលាយសំណល់សរីរាង្គ
ដូចជាកាកសំណល់ពណ៌បៃតង"។

ទោះបីជាយ៉ាងណាក៏ដោយសមត្ថភាពក្នុងការរំលាយរបស់ដីទៅលើកាកសំណល់
អាស្រ័យលើបរិមាណដែលបាននាំចូលមកដូចជា ស្ថានភាពអាកាសធាតុ
លក្ខណៈរបស់ដី និងភាវៈរស់ ។

*ដើម្បីស្វែងយល់បន្ថែម សូមចូលរួមក្នុង waste collage of the compost loop

# សម្ភារៈសំណង់



LA FRESQUE DU SOL
THE SOIL COLLAGE

ដី ឬធាតុផ្សំសំខាន់ៗរបស់ដីមួយចំនួនអាចយកមកប្រើប្រាស់ជាសម្ភារៈសំណង់។

ឧទា.
វត្ថុធាតុដើមកើតចេញពីធម្មជាតិត្រូវបានគេប្រើសម្រាប់ការសាងសង់( ដុំឥដ្ឋ ដុំថ្ម ឥដ្ឋតាន់ កំបោរ។ល។)

នៅដើមឆ្នាំ១៩៨០ វាត្រូវបានរកឃើញប្រមាណ១៥% នៃស្ថាបត្យកម្មបុរាណនៅប្រទេសបារាំង។

# ការផ្គត់ផ្គង់នគរូបនីយកម្ម



ដីផ្តល់នូវការផ្គត់ផ្គង់ជាច្រើនយ៉ាងដល់ការរស់នៅរបស់មនុស្ស។ យើងបានសាងសង់ផ្លូវជាច្រើនដែលផ្តល់ភាពងាយស្រួលក្នុងការធ្វើដំណើរទៅវិញទៅមក ការសាងសង់លំនៅដ្ឋាន និងការសាងសង់អគារ ។ល។

*ដើម្បីស្វែងយល់បន្ថែម សូមចូលរួមក្នុង the construction collage ឬthe city collage។

# សម្បត្តិវប្បធម៌



LA FRESQUE DU SOL
THE SOIL COLLAGE

ដីមានតួនាទីយ៉ាងសំខាន់ក្នុងការផ្ទុក និងថែរក្សាកេរ្តិ៍មរតក - ភូមិសាស្ត្រ ទេសភាព និងវប្បធម៌(វត្ថុបុរាណដែលនៅសេសសល់ ។ល។)

ពួកវាមានតួនាទីជាគ្រឹះយ៉ាងសំខាន់ទូទាំងសកលលោក និងថែមទាំងអាចផ្សាភ្ជាប់ទៅនឹងជំនឿផ្សេងៗ។

ពួកវាជាគ្រឹះ និងរក្សាទុកប្រវត្តិសាស្ត្ររបស់ពួកយើង។

# សិប្បនិម្មិត

39



សិប្បនិម្មិតសំដៅលើការផ្លាស់ប្តូរទាំងអស់
ឬផ្នែកណាមួយនៃមុខងាររបស់ដី( ជីវចម្រុះ វដ្តទឹក ការផ្គត់ផ្គង់អាហារ
និងបញ្ហាអាកាសធាតុ ។ល។) តាមរយៈការត្រួតត្រា
ឬការប្រើប្រាស់របស់មនុស្ស។

ដីសប្បនិម្មិតមានច្រើនកម្រិត ដែលកម្រិតខ្ពស់ជាងគេគឺការមិនជ្រាបទឹក។

*ដើម្បីស្វែងយល់បន្ថែម សូមចូលរួមក្នុង artificialisation collage។

# ការបំពុល

40



LA FRESQUE DU SOL
THE SOIL COLLAGE

ការបំពុលសំដៅលើការលេញឡើងខ្ពស់នូវសារធាតុ មិនប្រក្រតីណាមួយនៅក្នុងដី ដែលអាចប៉ះពាល់ដល់សុខភាពរបស់ភាវៈមានជីវិត(រួមបញ្ចូលទាំងមនុស្ស)។

សារធាតុពុលដែលមាននៅក្នុងដីអាចផ្លាស់ទីចូលទៅក្នុងទឹកក្រោមដី
និងចម្លងមេរោគទៅដល់សារពាង្គកាយទាំងអស់ដែលមាននៅទីនោះ
និងប្រព័ន្ធអេកូឡូស៊ី
ក៏ដូចជាទៅបំពុលខ្យល់តាមរយៈការភាយឡើងនៃចំហាយទឹក។

សារធាំតុបំពុលទាំងនេះជារើយៗកើតចេញពីសកម្មភាពរបស់ធម្មជាតិ(បន្ទុះភ្នំភ្លើង ។ល។) ប៉ុន្តែភាគច្រើនកើតចេញពីសកម្មភាពរបស់មនុស្ស។

# ការផ្លាស់ប្តូររបស់ទីតាំងភូមិសាស្ត្រ



LA FRESQUE DU SOL
THE SOIL COLLAGE

នៅពេលដែលយើងប្រើប្រាស់ដីក្នុងលក្ខណៈមួយផ្សេងទៀត មានន័យថាអ្នកផ្លាស់ប្តូរគុណសម្បត្តិ និងដំណើរការរបស់វា។

ការផ្លាស់ប្តូរតែងតែទទួលបានអត្ថប្រយោជន៍។ ទោះជាយ៉ាងណាក៏ដោយការផ្លាស់ប្តូរភាគច្រើននាពេលបច្ចុប្បន្ននេះជាលទ្ធផល ទទួលបានពីសកម្មភាពមនុស្សដែលបានជះឥទ្ធិពលអវិជ្ជមានទៅលើកាបូន តួនាទីរបស់វដ្តកាបូន និងបរិយាកាស។ ទឹក និងជម្រកធម្មជាតិ...

# ការគ្រប់គ្រងអាកាសធាតុនៅតាមតំបន់ និងពិភពលោក

42



LA FRESQUE DU SOL
THE SOIL COLLAGE

តាមរយៈការធ្វើរស្មីសំយោគ
រុក្ខជាតិបានទៅស្រូបយកកាបូនឌីអុកស៊ីតពីខ្យល់
និងអនុញ្ញាតឲ្យកាបូនមួយចំនួនផ្លាស់ទីទៅដីនៅពេលដែលពួកគេចាប់ផ្តើមរលួយក្រោមសកម្មភាពរបស់ភាវៈរស់នៅក្នុងដីនិងអាកាសធាតុ។

បន្ទុកដែលមាននៅក្នុងដីនេះអាចជួយកំណត់ឧស្ម័ននៅក្នុងផ្ទះកញ្ចក់ ដើម្បីទៅរក្សាសីតុណ្ហភាពក្នុងកម្រិតមួយដែលអាចឲ្យមនុស្សរស់នៅបាន ។

*ដើម្បីស្វែងយល់បន្ថែម សូមចូលរួមក្នុង The climate fresk។

# ការអភិរក្សភាខៈចម្រុះ



43

LA FRESQUE DU SOL
THE SOIL COLLAGE

ដីគឺជាជម្រកនៃភាវៈមានជីវិតទាំងអស់
ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការរក្សាតុល្យភាពនៃប្រព័ន្ធអេកូឡូស៊ីរប
ស់យើង។

ទំនាក់ទំនងរវាងគ្នា និងគ្នាបានចូលទៅដឹកនាំការធ្វើអន្តរកម្មរបស់ពួកគេ
(ការប្រកួតប្រជែងគ្នា សកម្មភាពរបស់ពពួកប៉ារ៉ាស៊ីត  ការវាយប្រហារ
ភាពស៊ីចង្វាក់គ្នា។ល។)។ ក្នុងចំណោមសកម្មភាពទាំងនេះ
ពួកវានាំមកនូវ វដ្តនៃសំណល់សរីរាង្គ ការកកើតឡើងនៃដី
ការលូតលាស់របស់រុក្ខជាតិ...

*ដើម្បីស្វែងយល់បន្ថែម សូមចូលរួមក្នុង The Biodiversity collage

# ការផលិតឱសថ



ដីជាកន្លែងដែលបានរកឃើញរឿងជាច្រើនយ៉ាង។

ក្នុងឆ្នាំ1943, ក្រុមការងាររបស់Selman Walksman បានរកឃើញ
ថ្នាំសម្លាប់មេរោគ(អង់ទីប៊ីយ៉ូទិច)
ដែលមានប្រសិទ្ធិភាពទៅប្រឆាំងនឹងជំងឺរបេង
តាមរយៈការសិក្សាស្រាវជ្រាវពីមីក្រូសារពាង្គកាយនៅក្នុងដី។

៧0%នៃថ្នាំសម្លាប់មេរោគ(អង់ទីប៊ីយ៉ូទិច)នេះ
ត្រូវបានបង្កើតឡើងតាមរយៈការសិក្សាស្រាវជ្រាវពីមីក្រូសារពាង្គកាយនៅក្នុងដី។

វាក៏បានជួយទៅដល់ការលូតលាស់នៃឱសថរុក្ខជាតិរបស់យើងផងដែរ។

# ការគ្រប់គ្រងគុណភាពរបស់ទឹក



តាមរយៈគុណសម្បត្តិរបស់វា (រូបរាង សារធាតុគីមី និងជីវសាស្រ្ត)
ដីបានទៅច្រោះទឹកដែលយើងផឹក
ហើយក៏បានទៅកំណត់គុណភាពរបស់វាផងដែរ។

នៅពេលដែលទឹកភ្លៀងធ្លាក់មកលើដី វាបានទៅចិញ្ចឹមរុក្ខជាតិ
ការរីងហួតហែង ការហៀរហូរចេញ និងការជ្រាបចូល។

វាជាជំនួយទៅដល់ទឹកនៅក្នុងដី ជាមធ្យម
៦០%នៅប្រទេសបារាំងដែលត្រូវបានផ្គត់ផ្គង់ជាទឹកសម្រាប់បរិភោគ។

# ការគ្រប់គ្រងលំហូរនៃទឹក និងស្តុកទុក



LA FRESQUE DU SOL
THE SOIL COLLAGE

សមាសភាពដីដែលមិនមានការបិតបាំង ឬរាំង(រចនាសម្ព័ន្ធ
រន្ធតូចៗនៅក្នុងដី បរិមាណនៃសំណល់សរីរាង្គ។ល។)
បានដើរតួយ៉ាងសំខាន់ជាចរន្តទឹក ៖ ផ្គត់ផ្គង់ដល់ទន្លេ កាត់បន្ថយទឹកជំនន់
រក្សាលំហូររបស់ទឹកឲ្យនៅកម្រិតទាប ។ល។

ប៉ុន្តែត្រូវតែមានការប្រុងប្រយ័ត្ន
ទោះបីជាពួកវាមានតួនាទីយ៉ាងសំខាន់ក្នុងការកំណត់ទឹកជំនន់ក៏ដោយ
តែពួកវាមិនអាចដោះស្រាយបញ្ហាដោយឯកឯងបានឡើយ។

# ការបំផ្លិចបំផ្លាញជីវចម្រុះ

47



LA FRESQUE DU SOL
THE SOIL COLLAGE

សកម្មភាពរបស់មនុស្សជាច្រើនបានចូលទៅកែប្រែលក្ខណៈសម្បត្តិរបស់ដី ហើយបានទៅកាត់បន្ថយជម្រករបស់ភាវៈរស់ដែលរស់នៅទីនោះ ឬក៏មានការគំរាមកំហែងទៅកាន់ពួកគេដោយផ្ទាល់។

ឧទា. ត្រឹម៣០%
នៃចំនួនអតិសុខុមប្រាណដែលមាននៅក្នុងដីអាចឈានដល់ការកាត់បន្ថ
យពាក់កណ្ដាលនៃដំណើរការលូតលាស់របស់រុក្ខជាតិ។

# ការរាំងស្ទះនៃវដ្តទឹក



តាមរយៈការកែប្រែលក្ខណៈសម្បត្តិរបស់ដី (រន្ធតូចៗក្នុងដី រចនាសម្ព័ន្ធ ។ល។)

ការប្រើប្រាស់ដីតាមវិធីមួយចំនួន អាចទៅរាំងស្ទះដល់វដ្តទឹក ដោយសារការកើនឡើងនៃការភាយចេញតាមរយៈចំហាយទឹក ឬក៏ការកាត់បន្ថយបន្ទុកនៅក្នុងដី

# ការរលាយនៃកំណកដី



LA FRESQUE DU SOL
THE SOIL COLLAGE

ផ្ទៃខាងលើនៃកំណកដី ( ដីដែលមិនមានចលនាយ៉ាងហោច២ឆ្នាំ )
ត្រូវបានប៉ាន់ស្មានថាមានចំនួន២០% នៃផ្ទៃដីទាំងមូល។

ការរលាយនៃកំណកដី
គឺជាផ្នែកមួយនៃការផលប៉ះពាល់ដល់ការឡើងកម្ដៅផែនដី។

ជាមួយនឹងការកើនឡើងនៃសីតុណ្ហភាព
កំណកដីត្រូវបានក្លាយជាធនធានយ៉ាងសំខាន់របស់កាបូននៅក្នុងបរិយា
កាស ក្នុងទម្រង់ជាឧស្ម័នកាបូនិច
ប៉ុន្តែក៏អាចជាឧស្ម័នមេតានដែលអាចពន្លើនដល់ការឡើងកម្ដៅរបស់ផែន
ដីក្នុងរយៈពេលកំណត់ណាមួយ។

# វាលខ្សាច់កម្ម



LA FRESQUE DU SOL
THE SOIL COLLAGE

វាលខ្សាច់កម្មគឺជាតំបន់ដែលសឹងតែពុំអាចស្រោចស្រង់បាន
ឬជាការបំផ្លាញនៃជីវសាស្ត្រដែលមានក្នុងដី
និងពុំមានសមត្ថភាពក្នុងការជួយទ្រទ្រង់ដល់ការរស់នៅរបស់ភាវៈមានជីវិ
តឡើយ។

វាកើតឡើងពីធម្មជាតិ (អាកាសធាតុ) និងការបង្កឡើងដោយមនុស្ស
(ការកាប់បំផ្លាញព្រៃឈើលើសចំណុះ ការចិញ្ចឹមសត្វ
ការបង្កបង្កើនផលលើដីហួសកំណត់ ។ល។)ការប្រើគ្រឿងចក្រ
(កម្រិតជាតិប្រៃ សំណឹកដី និងបង្ហាប់ដី។ល។)

# នៅផ្ទះ



LA FRESQUE
DU SOL
THE SOIL COLLAGE

# ការយល់ដឹង និងការលើកកម្ពស់ដី



LA FRESQUE
DU SOL
THE SOIL COLLAGE


ការសហប្រតិបត្តិការ

LA FRESQUE
DU SOL
THE SOIL COLLAGE

# ការអភិវឌ្ឍន៍កសិកម្ម
# និងព្រៃឈើប្រកបដោយនិរន្តរភាព



LA FRESQUE
DU SOL
THE SOIL COLLAGE

# ជំរុញឱ្យមានការណែនាំជាសាធារណៈពី ការអភិរក្សដី



LA FRESQUE
DU SOL
THE SOIL COLLAGE

# បង្កើតច្បាប់



LA FRESQUE DU SOL

THE SOIL COLLAGE

# ការសង្កេត និងរៀនសង្កេត



LA FRESQUE
DU SOL
THE SOIL COLLAGE

# ការកម្រិតភាពសិប្បនិម្មិតពីដី



LA FRESQUE
DU SOL
THE SOIL COLLAGE

# សាស្ត្រាចារ្យ



LA FRESQUE
DU SOL
THE SOIL COLLAGE

# កសិករ



LA FRESQUE
DU SOL
THE SOIL COLLAGE

# សិស្ស



LA FRESQUE DU SOL

THE SOIL COLLAGE

# អ្នកជំនួញ



LA FRESQUE
DU SOL
THE SOIL COLLAGE

# អាជីវករ



LA FRESQUE DU SOL

THE SOIL COLLAGE

# អ្នកសារព័ត៌មាន



LA FRESQUE DU SOL
THE SOIL COLLAGE

# ប្រជាពលរដ្ឋ



LA FRESQUE
DU SOL
THE SOIL COLLAGE

# អ្នកជាប់ឆ្នោត



LA FRESQUE
DU SOL
THE SOIL COLLAGE

# អ្នកអភិវឌ្ឍន៍



LA FRESQUE
DU SOL
THE SOIL COLLAGE



LA FRESQUE DU SOL
THE SOIL COLLAGE